ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩៩ ពណ.ប្រក.ព្រស

# ប្រកាស
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
# របស់នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម ស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មានមុខងារ និងភារកិច្ចដូចតទៅ៖

- ធ្វើជាសេនាធិការឲ្យអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម លើការងារជំរុញការអនុវត្តន៍កែលម្អ និងអភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្ម
- រៀបចំកសាងគោលនយោបាយពាណិជ្ជកម្ម សម្រាប់ការជំរុញការនាំចេញផលិតផល និងសេវាកម្មរបស់កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ
- សិក្សាស្រាវជ្រាវ និងវិភាគសកម្មភាពពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ព្រមទាំងផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយជំរុញពាណិជ្ជកម្ម ជូនក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

- ចូលរួមប្រជុំ និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ក្នុងគោលដៅស្វែងរកគោលនយោបាយល្អៗ សម្រាប់អភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា
- ចូលរួមកសាងគោលនយោបាយ ដើម្បីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមជាមួយស្ថាប័នពាក់ព័ន្ធ
- ផ្សព្វផ្សាយអំពីគោលនយោបាយជម្រុញពាណិជ្ជកម្ម តាមរយៈការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ជូនវិស័យឯកជន និងមន្ត្រីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតការយល់ដឹង និងចូលរួមអនុវត្តឲ្យបានទូលំទូលាយ ក្នុងគោលបំណងជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មរបស់កម្ពុជា
- លើកផែនការ និងកៀរគរជំនួយ ដើម្បីរៀបចំអនុវត្តគម្រោងពាក់ព័ន្ធនឹងការជំរុញពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ២** :

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣** :

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម មានការិយាល័យចំណុះ ចំនួន ០៤ គឺ៖

១- ការិយាល័យច្រកចូលទីផ្សារ

២- ការិយាល័យបរិយាកាសធុរកិច្ច

៣- ការិយាល័យកសាង និងគាំពារគោលនយោបាយ

៤- ការិយាល័យសម្របសម្រួល

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៤** :

ការិយាល័យច្រកចូលទីផ្សារ មានភារកិច្ច៖

- តាមដាន និងវិភាគការប្រែប្រួលគោលនយោបាយពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក ដើម្បីដាក់ចេញវិធានការក្នុងការទប់ស្កាត់ផលប៉ះពាល់ មកលើវិស័យនាំចេញរបស់កម្ពុជា
- សហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល ដើម្បីសិក្សា និងស្រាវជ្រាវពីអត្ថប្រយោជន៍នៃការអនុវត្តន៍កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី តំបន់ និងពាណិជ្ជកម្មពហុភាគី ដើម្បីលើកជាគោលនយោបាយ និងអនុសាសន៍ ជូនរាជរដ្ឋាភិបាលក្នុងគោលដៅជំរុញការនាំចេញរបស់កម្ពុជា

- ពិនិត្យ និងតាមដានលើការអនុវត្តន៍កម្មវិធីកាត់បន្ថយពន្ធគយរបស់តំបន់ និងកម្មវិធីកាត់បន្ថយពន្ធគយក្រោមក្របខ័ណ្ឌពាណិជ្ជកម្មសេរីផ្សេងទៀត សម្រាប់ធ្វើការផ្សព្វផ្សាយដល់អ្នកនាំចេញ
- តាមដាន និងត្រួតពិនិត្យការអនុវត្តន៍វិធានការបច្ចេកទេសមិនមែនពន្ធគយរបស់តំបន់ និងក្រៅតំបន់ រួមមានវិធានប្រភពដើមទំនិញ អនាម័យ ភូតគាមអនាម័យ និងស្តង់ដារសម្រាប់ផ្សព្វផ្សាយដល់អ្នកនាំចេញរបស់កម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៥** :

ការិយាល័យបរិយាកាសធុរកិច្ច មានភារកិច្ចៈ

- សិក្សា និងផ្តល់យោបល់អំពីផលប៉ះពាល់នៃការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិពាណិជ្ជកម្មជូនក្រសួងដើម្បីពិចារណា និងកែសម្រួល
- ចូលរួមជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិថ្មីៗ ទាក់ទងនឹងកិច្ចសម្រួលពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា
- តាមដាន និងធ្វើបច្ចុប្បន្នភាពជូនក្រសួងអំពីកាលានុវត្តភាពថ្មីៗ ទាក់ទងនឹងការអនុវត្តន៍វិធានការនានា នៃកិច្ចសម្រួលពាណិជ្ជកម្ម
- រៀបចំផ្សព្វផ្សាយអំពីបរិយាកាសធុរកិច្ច បទប្បញ្ញត្តិផ្សេងៗ និងកម្មវិធីកែទម្រង់របស់ក្រសួងពាណិជ្ជកម្មដល់ពាណិជ្ជករ និងអ្នកវិនិយោគ
- ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិនានា ទាក់ទងនឹងការវាយតម្លៃស្ថានភាពធុរកិច្ចនៅកម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៦** :

ការិយាល័យកសាង និងគាំពារគោលនយោបាយ មានភារកិច្ចៈ

- ស្រាវជ្រាវ និងរៀបចំគោលនយោបាយជំរុញពាណិជ្ជកម្មថ្មីៗ ដើម្បីជំរុញការនាំចេញផលិតផល និងសេវាកម្មសក្តានុពលរបស់កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ
- សិក្សា និងផ្តល់យោបល់លើការរៀបចំបង្កើតគោលនយោបាយនាំចូល ដើម្បីបម្រើការវិនិយោគនៅកម្ពុជា
- ចូលរួមផ្តល់យោបល់ និងការពារការអនុវត្តន៍គោលនយោបាយជំរុញពាណិជ្ជកម្ម ដែលបានដាក់ចេញដោយក្រសួងពាណិជ្ជកម្ម
- ចូលរួមជាមួយក្រសួង ស្ថាបន័ពាក់ព័ន្ធ ក្នុងការរៀបចំបង្កើតគោលនយោបាយថ្មីៗ ដើម្បីជំរុញពាណិជ្ជកម្ម

- រៀបចំផ្សព្វផ្សាយយុទ្ធសាស្ត្រ និងគោលនយោបាយជំរុញពាណិជ្ជកម្ម តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងវេទិកាផ្សេងៗ ដល់វិស័យឯកជន ផលិតករ អ្នកនាំចេញ កសិករ និងមន្ត្រីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៧ :**

ការិយាល័យសម្របសម្រួល មានភារកិច្ចៈ

- សហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរជំនួយសម្រាប់អនុវត្តគម្រោងជំរុញពាណិជ្ជកម្ម
- រៀបចំផែនការ និងកសាងគម្រោងស្រាវជ្រាវគោលនយោបាយជំរុញពាណិជ្ជកម្ម និងគម្រោងកសាងសមត្ថភាពមន្ត្រីក្នុងនាយកដ្ឋាន
- ទទួលការងារសម្របសម្រួល និងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៨ :**

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩ :**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

<u>កន្លែងទទួលៈ</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ដូចប្រការ ៩
-ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

